# សុន្ទរកថាបើកសម្រាប់វគ្គបច្ចេកទេស

**ឯកឧត្តម ខៀវ មុត រដ្ឋលេខាធិការក្រសួងបរិស្ថាន**

**វេទិកាជាតិលើកទី ៣ ស្តីពីការប្រែប្រួលអាកាសធាតុ**

សណ្ឋាគារសូហ្វីតែល ភោគីតត្រា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣

***សូមគោរព ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ!***

ជាបឋម ក្នុងនាមក្រសួងបរិស្ថាន និងជាអ្នកសម្របសម្រួលការរៀបចំកម្មវិធីនៃវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយជាអតិបរមា ដែលបានមកចូលរួមថ្លែងសុន្ទរកថាបើកវគ្គបច្ចេកទេសពេញអង្គទី១ នៃវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ ដ៏ឱឡារិកនេះ។ នៅក្នុងឱកាសវិសាលនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សមាជិក សមាជិកាអង្គវេទិកាទាំងមូលដែលបានចំណាយពេលដ៏មានតម្លៃ មកចូលរួមក្នុងព្រឹត្តិការណ៍ដ៏សំខាន់នេះ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!***

ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមដ៏ចំបងមួយ ដែលពិភពលោកកំពុងតែជួបប្រទះនាពេលបច្ចុប្បន្ន ហើយដែលតម្រូវឱ្យយើងចូលរួមដោះស្រាយ។ ប្រទេសទាំងអស់ទូទាំងពិភពលោកកំពុងរងផលប៉ះពាល់ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ដោយសារតែ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងរលកកំដៅ ដែលធ្វើឱ្យបាត់បង់ធ្ងន់ធ្ងរនូវអាយុជីវិត និងទ្រព្យសម្បត្តិ។ របកគំហើញថ្មីៗនេះរបស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុបានអះអាងឡើងវិញប្រកបដោយទំនុកចិត្តកម្រិតខ្ពស់ថា កំណើនការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពមនុស្ស គឺជាមូលហេតុចំបងនៃការប្រែប្រួលអាកាសធាតុ។ ប្រទេសនានានៅក្នុងតំបន់មេគង្គងាយរងគ្រោះនៅចំពោះមុខការប្រែប្រួលអាកាសធាតុ ដោយសារតែការប្រែប្រួលរបបជលសាស្ត្រទន្លេមេគង្គ ការថយចុះនៃកសិផល និងផលនេសាទ ការជ្រាបចូលនៃទឹកប្រៃ កំណើនចំនួនប្រជាជន ធនធានហិរញ្ញវត្ថុនិងបច្ចេកទេសមានកម្រិត ហេដ្ឋារចនាសម្ព័ន្ធរូបវន្តមិនសមស្រប និងសមត្ថភាពបន្សាំកម្រិតទាប។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះកាន់តែធ្ងន់ធ្ងរ និងញឹកញាប់ជាងមុន ដែលបានបង្កការប៉ះពាល់ធ្ងន់ធ្ងរមកលើសន្តិសុខស្បៀង របបចិញ្ចឹមជីវិតរបស់ប្រជាជន ហេដ្ឋារចនាសម្ព័ន្ធ និងសេដ្ឋកិច្ចសង្គមរបស់ជាតិជារួម។ ទឹកជំនន់ដ៏ធ្ងន់ធ្ងរនាពេលថ្មីៗនេះ បានបង្កការប៉ះពាល់មកលើខេត្ត ក្រុងស្ទើរតែទាំងអស់នៅក្នុងប្រទេសយើង ហើយបានបង្កឱ្យបាត់បង់អាយុជីវិតមនុស្ស និងការខូចខាតធ្ងន់ធ្ងរមកលើទ្រព្យសម្បត្តិ ផលដំណាំ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងរបរចិញ្ចឹមជីវិតរបស់សហគមន៍។ ទាំងអស់នេះគឺជាភស្តុតាងកាន់តែច្បាស់បន្ថែមទៀត ដែលបង្ហាញពីភាពធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ ហើយតម្រូវឱ្យចាត់វិធានការបន្ទាន់ដើម្បីឆ្លើយតប។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី !***

របាយការណ៍ជាតិលើកទី២ របស់កម្ពុជា ក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ បានសន្និដ្ឋានថា សីតុណ្ហភាព និងកម្ពស់ទឹកភ្លៀងនៅកម្ពុជាបានប្រែប្រួលរួចមកហើយ តាំងពីពាក់កណ្តាលចុងក្រោយនៃសតវត្សរ៍ទី២០ មក។ ការព្យាករណ៍សម្រាប់រយៈពេល៨០ ឆ្នាំ ខាងមុខបានបង្ហាញថា ប្រសិនបើពុំមានចាត់វិធានការជាដុំកំភួនណាមួយសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទេ នោះសីតុណ្ហភាពនៅកម្ពុជាទៅអនាគតនឹងបន្តកើនឡើង ចំណែករដូវវស្សានឹងកាន់តែមានភ្លៀងធ្លាក់ច្រើន តែក្នុងរយៈពេលខ្លីជាងមុន ហើយរដូវប្រាំងនឹងមានរយៈពេលកាន់តែវែង ហើយកាន់តែស្ងួតហែងជាងមុន។ នេះមានន័យថា កិច្ចប្រឹងប្រែងពីសំណាក់សហគមន៍អន្តរជាតិក្នុងការ

កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នឹងមានឥទ្ធិពលដោយផ្ទាល់មកលើអាកាសធាតុនៅកម្ពុជាទៅអនាគត។ កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំនេះ ពិភពលោកបានឃើញនូវកំហាប់ឧស្ម័នកាបូនិកក្នុងបរិយាកាសកើនដល់៤០០ភាគលានជាលើកដំបូង គិតចាប់តាំងពីពេលមនុស្សចាប់ផ្តើមកត់ត្រាជាលក្ខណៈប្រព័ន្ធ ដោយប្រើប្រាស់បរិក្ខារទំនើប។ នៅពេលដែលកំណើនឧស្ម័នផ្ទះកញ្ចក់ឈានដល់ចំណុចកំពូលជាប្រវត្តិសាស្ត្រនេះ យើងកំពុងតែឈានចូលក្នុងកម្រិតគ្រោះថ្នាក់ថ្មីមួយនៃកំណើនសីតុណ្ហភាពខ្ពស់ជាង២°C។ កំណើនសីតុណ្ហភាពបែបនេះនឹងនាំមកនូវផលវិបាកធំធេងមកលើវិស័យជាច្រើននៃសង្គមរបស់យើង និងបង្កឲ្យមានផលប៉ះពាល់ ដែលបណ្តាលមកពីទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះធ្ងន់ធ្ងរ ហើយញឹកញាប់ជាងមុន។ អាស្រ័យហេតុនេះ មានការអំពាវនាវជាច្រើនលើសលុប ដើម្បីឲ្យចាត់វិធានការជាបន្ទាន់ សំដៅកាត់បន្ថយហានិភ័យ និងកាត់បន្ថយកម្រិតធ្ងន់ធ្ងរនៃផលប៉ះពាល់ ជាពិសេស ផលប៉ះពាល់មកលើបេចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋភាគច្រើនរបស់យើង ដែលរស់នៅតាមជនបទ និងដែលងាយរងគ្រោះបំផុត។

***ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីមេត្រី!***

កម្ពុជាបាន និងកំពុងចូលរួមយ៉ាងសកម្មនៅក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ទាំងនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ នៅថ្នាក់ជាតិ យើងបានបន្តពង្រឹងសមត្ថភាពគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលមានអាណត្តិសម្របសម្រួលវិធានការជាតិ សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ គឺជាអាទិភាពចំបង នៅក្នុងរបៀបវារៈរបស់រាជរដ្ឋាភិបាល។ ការបង្កើតផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ដែល **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីព្រឹកមិញនេះ គឺជាជំហានដ៏សំខាន់មួយ ឆ្ពោះទៅរកការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅក្រោយឆ្នាំ២០១៥ និងការរួមបញ្ចូលសមាហរណកម្មបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យរបស់ក្រសួងពាក់ព័ន្ធ។ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាសម្រាប់រយៈពេល១០ឆ្នាំ ២០១៤-២០២៣ កំណត់ចក្ខុវិស័យយ៉ាងច្បាស់លាស់មួយសម្រាប់រយៈពេលវែង ពោលគឺ "***កម្ពុជាអភិវឌ្ឍន៍ទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល***"។ ផែនការនេះនឹងផ្តល់នូវក្របខ័ណ្ឌគោលនយោបាយជាយុទ្ធសាស្ត្រមួយ សម្រាប់តម្រង់ទិស និងគាំទ្រស្ថាប័នជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងការគិតគូរអំពីវិធានការជាក់លាក់ និងសមស្រប ដែលទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការអភិវឌ្ឍបៃតង និងការអភិវឌ្ឍដែលបញ្ចេញកាបូនតិច ដែលគាំទ្រដល់សមិទ្ធិផលនៃយុទ្ធសាស្ត្រចតុកោណ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា។

ព្រឹកមិញនេះ នៅក្នុងពិធីបើកវេទិកា ដែលប្រព្រឹត្តិទៅនៅវិមានសន្តិភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបកស្រាយគោលការណ៍នាំមុខសំខាន់ៗចំនួនបីសម្រាប់វិធានការរបស់យើងដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅរយៈពេល៥ឆ្នាំខាងមុខ នៅក្នុងអាណត្តិទី៥នៃរាជរដ្ឋាភិបាល កម្ពុជា និងបណ្តាឆ្នាំក្រោយៗទៀត ជាអាទិ៍៖

- ភាពចាំបាច់នៃការប្រើប្រាស់វិធីសាស្ត្រពហុជំនាញ និងកិច្ចសហការជាមួយស្ថាប័ននានា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការសកម្មភាព។

- សារៈសំខាន់នៃការគិតគូរជាលក្ខណៈប្រព័ន្ធពីសំណាក់ក្រសួងនានា និងដៃគូអភិវឌ្ឍន៍ អំពីបញ្ហាប្រែប្រួលអាកាសធាតុ នៅពេលបង្កើតអន្តរាគមន៍អភិវឌ្ឍន៍ថ្មីៗ ដើម្បីធានាថា យើងនៅតែសម្រេចគោលដៅអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចរបស់យើង នៅក្នុងបរិការណ៍នៃការប្រែប្រួលអាកាសធាតុ។
- ការតម្រូវឲ្យអ្នកពាក់ព័ន្ធទាំងអស់ធ្វើការជិតស្និទ្ធជាមួយគ្នាក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ តាមបែបវិទ្យាសាស្ត្រ និងការផ្លាស់ប្តូរចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ ដើម្បីកសាងធនធានមនុស្ស និងគាំទ្រដល់ការធ្វើសេចក្តីសម្រេចដែលផ្អែកលើចំណេះដឹង។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី !*

ខ្ញុំមានសេចក្តីរីករាយណាស់ចំពោះការចូលរួមរបស់អ្នកជំនាញការជាតិ និងអន្តរជាតិទាំងអស់ ដែលនឹងធ្វើបទបង្ហាញចែករំលែកបទពិសោធន៍ និងចូលរួមនៅក្នុងការពិភាក្សាលើប្រធានបទធំៗ ដូចជា វិទ្យាសាស្ត្រប្រែប្រួលអាកាសធាតុ ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ គោលនយោបាយប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាព ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និងប្រធានបទអន្តរវិស័យនានាជាច្រើនផ្សេងទៀត។ ខ្ញុំក៏មានសេចក្តីរីករាយផងដែរ ដែលបានឃើញការចូលរួមយ៉ាងសកម្មពីសំណាក់វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការតាំងបង្ហាញផលិតផលមេត្រីភាពអាកាសធាតុរបស់ខ្លួន។ នេះជាសញ្ញាវិជ្ជមានមួយ ដែលបង្ហាញថា វិស័យឯកជននៅកម្ពុជាមានការយល់ដឹងកាន់តែច្រើនឡើងអំពីអំពីឱកាសខាងទីផ្សារ និងតួនាទីមិនអាចខ្វះបានរបស់វិស័យឯកជន នៅក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ហើយភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន គឺជាមូលដ្ឋានគ្រឹះដើម្បីធានាប្រសិទ្ធភាព និងភាពផ្តល់ផលនៃវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា ក្នុងរយៈពេលពីរថ្ងៃកន្លះខាងមុខនេះ អ្នកចូលរួមទាំងអស់ នឹងមានឱកាសដើម្បីទទួលបានចំណេះដឹងជាក់ស្តែង ជំនាញ ព័ត៌មាន និងបទពិសោធន៍នានាកាន់តែច្រើនជាងមុន និងអាចចូលរួមយ៉ាងសកម្មនៅក្នុងការពិភាក្សាលើប្រធានបទសំខាន់ៗ ដើម្បីរួមចំណែកពង្រឹងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ការចូលរួមយ៉ាងសកម្មរបស់ឯកឧត្តម ជំទាវ លោក លោកស្រី នៅទីនេះ ឆ្លុះបញ្ចាំងអំពីការប្តេជ្ញាមោះមុតក្នុងការដោះស្រាយបញ្ហាប្រឈមនានា បង្កដោយការប្រែប្រួលអាកាសធាតុ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ។ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា យើងនឹងរួបរួមគ្នាដើម្បីអភិវឌ្ឍកម្ពុជា ឆ្ពោះទៅរកសង្គមមួយ ដែលបៃតង បញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល ។

នៅទីបញ្ចប់ ក្នុងនាមក្រសួងបរិស្ថាន និងក្រុមការងាររៀបចំវេទិកានេះ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី បានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ និងសូមឲ្យវេទិកានេះប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា និងការស្ថាបនា។

សូមអរគុណ!